ឯកសារដែលត្រូវការសំរាប់ការស្នើសុំទិដ្ឋាការស្នាក់នៅរយៈពេលខ្លី

<u>ការស្នើសុំទៅលេងបងប្អូន ។ល។</u> To visit relatives etc.

◙ *ឯកសារដែលអ្នកដាក់ពាក្យស្នើសុំទិដ្ឋាការត្រូវរៀបចំ*

១ – លិខិតឆ្លងដែននៅមានសុពលភាព

២– ពាក្យស្នើសុំទិដ្ឋាការមួយសន្លឹកដោយមានបិតរូបថតសាម៉ីខ្លួនអ្នកដាក់ពាក្យ

៣ – សំបុត្រយន្តហោះទៅ–មក ឬ ក្រដាសបញ្ជាក់ពីការកក់សំបុត្រយន្ត ហោះទៅ–មក

៤– សៀវភៅស្នាក់នៅ ឬ សៀវភៅគ្រួសារ ដោយភ្ជាប់ជាមួយការបកប្រែជាភាសាអង់គ្លេស ឬ ភាសាជប៉ុន

៥– សេចក្តីចម្លងសំបុត្រកំណើត ឬ សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ជាដើម ដែលជាឯកសារបញ្ជាក់អំពីទំនាក់ទំនងគ្រួសារ (បើអ្នកធានាជាសញ្ជាតិជប៉ុនហើយមានប័ណ្ណគ្រួសារពីខាងជប៉ុនដែលអាចបញ្ជាក់អំពីទំនាក់ទំនងគ្រួសារបាន មិនចាំបាច់ឯកសារពីខាងកម្ពុជា )

៦ – ឯកសារបញ្ជាក់លទ្ធភាពអាចរ៉ាប់រងការចំណាយ ដូចជាលិខិតបញ្ជាក់សមតុល្យក្នុងគណនីនៅធនាគារ សៀវភៅគណនីបញ្ញើសំចៃជាដើម (ក្នុងករណីសាម៉ីខ្លួនអ្នកដាក់ពាក្យរ៉ាប់រងសោហុយដោយខ្លួនឯង)

◙ *ឯកសារដែលអ្នកធានានៅប្រទេសជប៉ុនត្រូវរៀបចំ*

១ – លិខិតបញ្ជាក់ពីមូលហេតុនៃការអញ្ជើញ

២– ប័ណ្ណគ្រួសារជប៉ុន (ក្នុងករណីអ្នកអញ្ជើញជាសញ្ជាតិជប៉ុន)

៣ – លិខិតធានា

៤– លិខិតបញ្ជាក់ប្រាក់ចំណូលចេញដោយអាជ្ញាធរក្រុង ខណ្ឌសង្កាត់ ឬ លិខិតបញ្ជាក់សមតុល្យក្នុងគណនីនៅធនាគារ (ក្នុងករណីអ្នកធានាជាអ្នករ៉ាប់រងចេញសោហុយឱ្យ)

៥– លិខិតបញ្ជាក់ទីលំនៅ (មានសុពលភាពក្នុងរង្វង់៣ខែពីថ្ងៃផ្តល់លិខិត ក្នុងករណីអ្នកធានាជាជនបរទេសអន្តោប្រវេសន៍ លិខិតបញ្ជាក់ការស្នាក់នៅ និង លិខិតឆ្លងដែនថតចម្លង។

*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*

*ពេលម៉ោងធ្វើការសំរាប់ការដាក់ពាក្យស្នើសុំទិដ្ឋាការ*

*ពេលព្រឹកៈ ០៨:០០ – ១២:០០*

*ពេលរសៀល ១៤:០០ – ១៦:៣០*

*ពីថ្ងៃ ច័ន្ទ ដល់ថ្ងៃ សុក្រ នៅផ្នែក កុងស៊ុល*